## លំនៅដ្ឋាន

- នៅពេលមានការអំពាវនាវឱ្យប្រជាជននៅក្នុងផ្ទះ វាជាការសំខាន់ណាស់ដែលរដ្ឋាភិបាលទាំងឡាយចាត់វិធានការបន្ទាន់ ដើម្បីជួយប្រជាជនដែលគ្មានផ្ទះសម្បែងសមរម្យ ព្រោះការនៅផ្ទះ និងការរក្សាគំលាតរាងកាយឆ្ងាយពីគ្នា គឺពិបាកខ្លាំងចំពោះបុគ្គលទាំងឡាយដែលរស់នៅក្នុងស្ថានភាពចង្អៀតណែនអ្នកគ្មានផ្ទះសម្បែង និងអ្នកដែលខ្វះលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ។ ការអនុវត្តន៍ល្អសម្រាប់ការពារបុគ្គលទាំងឡាយដែលរស់នៅក្នុងលំនៅដ្ឋានមិនសមរម្យ និងជនអនាថា រួមមាន ការផ្តល់កន្លែងស្នាក់នៅដែលអាចប្រើប្រាស់ជាបន្ទាន់ (រួមទាំង ការប្រើប្រាស់អគារលំនៅដ្ឋានដែលទុកទំនេរចោលសម្រាប់ជួលរយៈពេលខ្លី) ដែលមានសេវាសម្រាប់អ្នកដែលរងផលប៉ះពាល់ពីមេរោគ ហើយត្រូវតែនៅដាច់ឆ្ងាយពីគេ។
- អាជ្ញាធរ គួរចាត់វិធានការតាមគោលដៅ ដើម្បីការពារប្រជាជនកុំឱ្យក្លាយជាមនុស្សគ្មានផ្ទះសម្បែង ឧទាហរណ៍ដូចជា ប្រជាជនប្រឈមនឹងការបណ្តេញចេញនៅពេលដែលបាត់បង់ប្រាក់ចំណូល ធ្វើឱ្យពួកគេមិនអាចបង់រំលស់ និងបង់ថ្លៃជួលបាន។ ការអនុវត្តល្អ ដូចជា ការផ្អាកការបណ្តេញចេញ និងការពន្យាពេលនៃការទូទាត់ប្រាក់កម្ចីមានទ្រព្យបញ្ចាំ គួរត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ។
- នៅពេលណានិងកន្លែងណាដែលមានការពង្រឹងវិធានការទប់ស្កាត់ គ្មាននរណាម្នាក់គួរត្រូវបានដាក់ទោសទណ្ឌឡើយ ព្រោះពួកគេគ្មានផ្ទះសម្បែង ឬរស់នៅក្នុងលំនៅដ្ឋានដែលមិនសមរម្យ។